ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ...៥៩...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកាត់ដីទំហំ ១ ២១៩ ហិកតា ៩៦ អា ចេញពីដីរដ្ឋដែលជាអតីតដីសម្បទានសេដ្ឋកិច្ច របស់ក្រុមហ៊ុនអភិវឌ្ឍន៍ដំណាំឧស្សាហកម្ម អ៊ុក ឃុន និងធ្វើអនុបយោគដីទំហំ ១ ១៣២ ហិកតា ២៣ អា ជាដីឯកជនរបស់រដ្ឋ ដើម្បីប្រទានកម្មជូនប្រជាពលរដ្ឋចំនួន ៥៩៥ គ្រួសារ និងរក្សាទុកទំហំ ៨៧ ហិកតា ៧៣ អា ជាដីសាធារណៈរបស់រដ្ឋ ព្រមទាំងផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី ស្ថិតនៅភូមិទី១ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា១ .-**

កាត់ផ្ទៃដីសរុបទំហំ ១ ២១៩ ហិកតា និង ៩៦ អា ចេញពីដីរដ្ឋដែលជាអតីតដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនអភិវឌ្ឍន៍ដំណាំឧស្សាហកម្ម អ៊ុក ឃុន និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផលជាក់ស្តែង ទំហំ ១ ១៣២ ហិកតា និង ២៣ អា និងរក្សាទុកជាដីសាធារណៈរបស់រដ្ឋ ទំហំ ៨៧ ហិកតា និង ៧៣ អា ស្ថិតនៅភូមិទី១ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ។

**មាត្រា២ .-**

ប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៥៩៥ គ្រួសារ នៅភូមិទី១ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។

**មាត្រា៣ .-**

ផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុបចំនួន ៨៥៩ ក្បាលដី ក្នុងនោះ ក្បាលដីចំនួន ៧៤៩ ក្បាលដី ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ៥៦៨ គ្រួសារ ផ្តល់កម្មសិទ្ធិជាទ្រព្យរបស់វត្តចំនួន ១ ក្បាលដី និងផ្តល់សិទ្ធិកម្មសិទ្ធិសាធារណៈរបស់រដ្ឋចំនួន ៤ ក្បាលដី គឺដីសាលារៀនចំនួន ១ ក្បាលដី ដីស្នងការចំនួន ២ ក្បាលដី និងដីមជ្ឈមណ្ឌលហ្វឹកហ្វឺនចំនួន ១ ក្បាលដី ស្ថិតនៅភូមិទី១ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។

ដោយឡែកក្បាលដីចំនួន ១០៥ ក្បាលដី ពុំទាន់អាចចុះបញ្ជីនិងចេញបណ្ណជូនបាន ក្នុងនោះ ៨០ ក្បាលដី ជាក្បាលដីគ្មានទិន្នន័យប្រគល់ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តគ្រប់គ្រងថែរក្សាការពារជាទ្រព្យសម្បត្តិរដ្ឋឱ្យមានប្រសិទ្ធភាព ២២ ក្បាលដី ជាដីទំនាស់មិនទាន់ដោះស្រាយបាន និង ៣ ក្បាលដី ជាក្បាលដីធំជាង ១០ ហិកតា នឹងធ្វើការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ ជាក្រោយ។

**មាត្រា៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៨ រោច ខែ[illegible] ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែ[illegible] ឆ្នាំ២០២១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

